**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

## ផ្ញើជូន

លោកជំទាវ **ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

និងស្វាមី

*លោកជំទាវជាទីរាប់អាន,*

ភរិយាខ្ញុំ និងរូបខ្ញុំបានទទួលដំណឹងដ៏ក្រៀមក្រំថា លោកព្រឹទ្ធាចារ្យ **ឆេង ផុន** ដែលត្រូវជាឪពុកក្មេករបស់លោកជំទាវ បានទទួលមរណភាព ក្នុងជន្មាយុ ៨៧ ឆ្នាំ ដោយជរាពាធ ។

មរណភាពរបស់លោកព្រឹទ្ធាចារ្យ គឺជាការបាត់បង់បិតា ជីតា ប្រកបដោយព្រហ្មវិហារធម៌ និងក៏ជាការបាត់បង់នូវធនធានមនុស្សដ៏សំខាន់ម្នាក់របស់ជាតិ ដែលលោកធ្លាប់បានចូលរួមចំណែកយ៉ាងថ្លៃថ្លាក្នុងការរៀបចំប្រទេសជាតិ តាមរយៈការធ្វើជារដ្ឋមន្ត្រីក្រសួងវប្បធម៌ និងបន្ទាប់មកជាប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ក្នុងឱកាសប្រកបដោយសមានទុក្ខដ៏ក្រៀមក្រំនេះ ភរិយាខ្ញុំ និងរូបខ្ញុំ សូមចូលរួមចែករំលែកនូវមរណទុក្ខដោយក្តីស្រណោះ និងការអាឡោះអាល័យជាមួយលោកជំទាវ ស្វាមី និងបុត្រា បុត្រី ព្រមទាំងបងប្អូនកូនក្មួយទាំងអស់នៃសព ដោយសេចក្តីសង្វេគជាទីបំផុត ។

ភរិយាខ្ញុំ និងរូបខ្ញុំ សូមឧទ្ទិសបួងសួងអោយដួងវិញ្ញាណក្ខន្ធព្រឹទ្ធាចារ្យ **ឆេង ផុន** បានចាប់កំណើតកើតក្នុងសុគតិភពគ្រប់ៗជាតិ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមលោកជំទាវទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីភរិយាខ្ញុំ និងរូបខ្ញុំ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១៦*

**ហ៊ុន សែន**